**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីឧបទ្ទវហេតុគ្រោះថ្នាក់ចរាចរណ៍ នៅតាមផ្លូវជាតិលេខ៤១
## ព្រំប្រទល់ស្រុកគងពិសី និងស្រុកសំរោងទង ខេត្តកំពង់ស្ពឺ
## ថ្ងៃទី១២ ខែមករា ឆ្នាំ២០១៦

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈមានក្តីរន្ធត់ និងក្រៀមក្រំយ៉ាងក្រៃលែងនៅពេលទទួលបានព័ត៌មានថា មានឧបទ្ទវហេតុគ្រោះថ្នាក់ចរាចរណ៍ដ៏រន្ធត់មួយបានកើតឡើងនៅតាមបណ្តោយផ្លូវជាតិលេខ៤១ ត្រង់ចំណុចភូមិជ្រៃត្រកួន ឃុំរកាកោះ ស្រុកគងពិសី ជាប់ព្រំប្រទល់នឹងស្រុកសំរោងទង កាលពីវេលាម៉ោង ០៦:៣០ព្រឹក ថ្ងៃទី១២ ខែមករា ឆ្នាំ២០១៦នេះ។ គិតត្រឹមម៉ោង១១:០០នាទីព្រឹកនេះមានកម្មករ-កម្មការិនី បម្រើការងារនៅរោងចក្រ NOUW CORP ចំនួន៥នាក់ ស្លាប់បាត់បង់ជីវិត និងចំនួន៦៨នាក់បានរងរបួស។

ឆ្លៀតក្នុងឱកាសដ៏សែនក្រៀមក្រំនេះ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមចូលរួមរំលែកនូវសេចក្តីទុក្ខក្រៀមក្រំ ក្តុកក្តួល សោកស្តាយ អាឡោះអាល័យជាទីបំផុតជាមួយក្រុមគ្រួសារ និងញាតិមិត្តទាំងអស់របស់ជនរងគ្រោះ ហើយសូមបួងសួងដល់វិញ្ញាណក្ខន្ធកម្មករ-កម្មការិនី ដែលទទួលមរណភាពបានសោយសុខក្នុងសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ ហើយជូនពរឱ្យអ្នកដែលរងរបួសឆាប់បានជាសះស្បើយ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបាននឹងកំពុងបញ្ជូនគណៈប្រតិភូជាន់ខ្ពស់ចុះទៅសួរសុខទុក្ខព្រមទាំងជួយដោះស្រាយទុក្ខលំបាករបស់បងប្អូនកម្មករ-កម្មការិនី និងក្រុមគ្រួសារទៅតាមគោលរបបសន្តិសុខសង្គមរបស់បេឡាជាតិរបបសន្តិសុខសង្គម។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១២ ខែមករា ឆ្នាំ២០១៦*

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទៈ(០២៣)៨៨ ៤៣ ៧៥ និងទូរសារៈ(០២៣)៨៨ ២៧ ៦៩